ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨៦

ចុះថ្ងៃទី ៣១_០១_២០១២

សាលដីកា

លេខ : ៤៣ "ក្រ.III.ស"

ចុះថ្ងៃទី ១៥_០៦_២០១២

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

**********

សវនាការជាសាធារណៈ នៅថ្ងៃទី ២១_០៥_២០១២ ដោយមានសមាសភាពដូចខាងក្រោមៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៨៦ ចុះថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១២ ដែលមានៈ

- ជនជាប់ចោទឈ្មោះ [redacted] ចន្ទ ភេទស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ មុខរបរបើកកន្លែងម៉ាស្សា កើតនៅភូមិម្ងង ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ទីលំនៅមុនពេល[redacted]សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] មានកូន ២នាក់ ទោសពីមុនគ្មាន ឃាត់ខ្លួនថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ ឃុំខ្លួនថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ២០១១ បច្ចុប្បន្ននៅ ម២។

មានលោក [redacted]ណ្ណរិទ្ធ ជាមេធាវីការពារ។

**<u>ជាប់ចោទពីបទៈ</u> សញ្ញារកម្មមានស្ថានទម្ងន់ទោស (ប្រព្រឹត្តបុគ្គលច្រើននាក់ធ្វើពេស្យាចារ)** ប្រព្រឹត្តនៅផ្ទះលេខ ១៩E₀ ផ្លូវស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ២៨៨ នៃក្រមព្រហ្មទណ្ឌ។

**ដំណើររឿងមានដូចតទៅៈ**

កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ១៦ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចុះធ្វើការបង្ក្រាប និងឆែកឆេរទីតាំងម៉ាស្សាកោសជប់ និងមានរូមភេទ ស្ថិតនៅផ្ទះលេខ ១៩E₀ ផ្លូវស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ពេលចុះធ្វើការឆែកឆេរគណៈកម្មការចម្រុះធ្វើការឆែកឆេរឃើញវត្ថុតាង ដូចជា ៖

ស្រោមអនាម័យប្រើរួចចំនួន ១ ស្រោមអនាម័យមិនទាន់ប្រើមួយចំនួន និងសៀវភៅកត់ត្រាចំនួន ២ក្បាល ហើយសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនថៅកែម៉ាស្សា និងអញ្ជើញនារីម៉ាស្សាបម្រើផ្លូវភេទចំនួន ៧នាក់ ដើម្បីធ្វើការសាកសួរ និងស្រាវជ្រាវ ក្រោយពីធ្វើការសាកសួរថៅកែម៉ាស្សា និងនារីម៉ាស្សា រួចសន្និដ្ឋានបានថា ឈ្មោះ [redacted] ចន្ទ ភេទស្រី អាយុ ៤០ឆ្នាំ ពិតជាបានយកថ្លៃឈ្នួលរួមភេទពីនារីម៉ាស្សាពិតមែន។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៤០ កបព "ទ" ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១- ផ្តន្ទាទោសឈ្មោះ [redacted] **ចន្ទ** ភេទស្រី អាយុ ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគារចំនួន ០២ (ពីរ) ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរធម្មតា ពីបទ **សញ្ចារកម្មមានស្ថានទម្ងន់ទោសប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ** ប្រព្រឹត្តនៅផ្ទះលេខ ១៩E₀ ផ្លូវស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ តាមបញ្ញត្តិមាត្រា ២៨៤ មាត្រា ២៨៨ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២- វត្ថុតាងមានដូចក្នុងកំណត់ហេតុទទួលវត្ថុតាងពីចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញលេខ ៧០០ វត ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១១ មានស្រោមអនាម័យមិនទាន់ប្រើមួយចំនួន និងស្រោមអនាម័យប្រើរួចចំនួនមួយ និងសៀវភៅសម្រាប់កត់ត្រាចំនួនពីរក្បាល រឹបអូសបំផ្លាញចោល។

សាលក្រមនេះជំនុំជម្រះជាសារណៈនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចន្ទ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៤០ ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **ចន្ទ** ជាជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៤០ កបព "ទ" ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ជនជាប់ចោទឈ្មោះ [redacted] **ចន្ទ** ឆ្លើយថា: ខ្លួនប្តឹងឧទ្ធរណ៍មក ព្រោះខ្លួនមិនសុខចិត្ត ខ្លួនរកស៊ីស្របច្បាប់ មានលិខិតអនុញ្ញាតត្រឹមត្រូវ កន្លែងខ្លួនរកស៊ីមិនមានបន្ទប់ទេ មានតែរបាំងមិនមានទ្វារទេ ចំពោះស្រោមអនាម័យ គឺអង្គការចែកឱ្យទេ។ ផ្ទះខ្លួនមានប្រាំបន្ទប់ តែអត់មានទ្វារទេ បន្ទប់ថ្មមានពីរ បន្ទប់ឈើមានបី ស្រីកោសជប់មាន ៧នាក់ កោសជប់ម្នាក់មួយម៉ឺនរៀល ក្នុងម្នាក់ខ្លួនយក ៧០០០រៀល អ្នកកោស ៣០០០រៀល ក្នុង ១ម៉ោង។ ជូនកាលភ្ញៀវកោសខ្យល់ហើយម៉ាស្សាថែមមួយម៉ោង គិតថែមមួយម៉ឺនរៀលទៀត។ ក្រៅពីម៉ាស្សា កោសជប់មិនមានរួមភេទទេ ចំណែកការរួមភេទនៅ

ខាងក្រៅខ្លួនអត់ដឹងទេ។ ខ្លួនទទួលបាយទឹកហូបចុក និងពេលចេញក្រៅខ្លួនមិនដែលបានយកកម្រៃពីពួកនាង១ទេ ចំពោះឈ្មោះ [redacted] ចាន់ធឿន ខ្លួនស្គាល់។ ខ្លួនមិនដែលទទួលកម្រៃពីការរួមភេទរបស់ស្រី១ទេ តែភ្ញៀវតាមផ្ទះសំណាក់ខ្លះយកស្រី១ទៅកោសជប់នៅខាងក្រៅ ដោយយកម្តងមួយម៉ឺនរៀល ខ្លួនបានបើកម៉ាស្សារយៈពេលបីឆ្នាំមកហើយ ចំពោះស្រោមអនាម័យខ្លួនមិនដែលមានទេ ហើយបើរួមភេទមិនមែនយកលុយមួយម៉ឺនរៀលនោះទេ។ សំណូមពរ សុំតុលាការលើកលែងឱ្យខ្លួនផង ដើម្បីខ្លួនបានទៅមើលថែកូន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] ចន្ទ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ យល់ឃើញថា មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ដូច្នេះ សុំឱ្យក្រុមប្រឹក្សាពិចារណាតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

នៅក្នុងអាជីវកម្មកោសជប់ កូនក្តីខ្លួនបានជួលផ្ទះគេ ហើយភ្ញៀវមកកោសជប់យកតម្លៃមួយម៉ឺនរៀល ហើយម្ចាស់ផ្ទះបាន ៧០០០រៀល ស្រី១យក ៣០០០រៀល ព្រោះផ្ទះម្ចាស់ទទួលផ្ទះឱ្យស្នាក់ បាយ ទឹក ភ្លើង ទឹកជាដើម។ បន្ទប់របស់ម្ចាស់ផ្ទះគ្មានទ្វារទេ ហើយគាត់ដឹងថា ការទទួលរួមសិច គឺខុស ដូចនេះ គាត់មិនទទួលទេ ហើយបើភ្ញៀវចេញទៅក្រៅឱ្យលុយបានមួយម៉ោង ១០០០០រៀល ពីរម៉ោងបាន ២០០០០រៀល បីម៉ោង ៣០០០០រៀល បួនម៉ោង ៤០០០០រៀល ព្រោះកូនក្តីខ្លួនមិនបិទសេរីភាពស្រី១ទេ ហើយបើគាត់មិនធ្វើអញ្ចឹងទេ គឺគាត់មិនមានប្រាក់សម្រាប់ផ្គត់ផ្គង់បាយទឹកភ្លើងទេ ហើយការចេញទៅក្រៅទៅរួមសិច ឬទៅធ្វើអីនោះ គឺកូនក្តីខ្លួនគាត់អត់បានទទួលផលនោះទេ ហើយការចេញទៅក្រៅគាត់មិនចំណាយលើទឹកភ្លើងទេ។ មន្ត្រីនគរបាលមានបីនាក់គាត់ជាសាក្សី តើគាត់អាចក្លាយទៅជាសាក្សីបានទេ គាត់ជាអ្នកដាក់បន្ទុក ដូចនេះ គាត់មិនអាចក្លាយទៅជាសាក្សីបានឡើយ។ គ្មានសាក្សីណាម្នាក់អះអាងថា គ្មានបានទៅរួមភេទជាមួយភ្ញៀវនោះទេ មានតែម្នាក់ដែលឆ្លើយទាំងស្រពិចស្រពិលប៉ុណ្ណោះ។ គ្មានសាក្សីណាម្នាក់ឆ្លើយថា មានការរួមសិចទេ។ នៅក្នុងអំពើសញ្ចារកម្ម គឺមានទោស ២ឆ្នាំ ទៅ ៣ឆ្នាំ តែតុលាការបានសម្រេចផ្តន្ទាទោសរហូតដល់ ៥ឆ្នាំ និងទោសគុក ២ឆ្នាំ គឺមិនត្រឹមត្រូវទេ បើកូនក្តីខ្លួនប្រព្រឹត្តក៏ទោសគាត់មិនអាចដល់ ៥ឆ្នាំ ដែរ តែនេះគាត់មិនបានប្រព្រឹត្តឡើយ ដូច្នេះ សូមក្រុមប្រឹក្សាពិចារណាឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ហើយកូនក្តីខ្លួនបានជាប់គុក ១១ខែ មកហើយ សូមដោះលែងកូនក្តីខ្លួនដើម្បីឱ្យគាត់មានសេរីភាព និងទៅមើលថែទាំកូន។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា រិះគន់ ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៤០ ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ចន្ទ ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ សមត្ថកិច្ចនគរបាលបានចុះធ្វើការឆែកឆេរផ្ទះលេខ ១៩E₀ ស្ថិតនៅផ្លូវស៊ីសុវត្ថិ សង្កាត់ស្រះចក ជាហាងកោសជប់ ម៉ាស្សា មានឈ្មោ[redacted] ចន្ធូ ជាជនជាប់ចោទ ជាម្ចាស់គ្រប់គ្រង។ ប្រតិបត្តិការនេះសមត្ថកិច្ចបានចាប់ខ្លួនជនជាប់ចោទជាម្ចាស់ហាង។

- តាមការអះអាងរបស់ជនជាប់ចោទថា ខ្លួនជួលផ្ទះលេខ ១៩E₀ នេះបើកអាជីវកម្មម៉ាស្សាកោស ជប់ខ្យល់រយៈពេល ០១ឆ្នាំ មកហើយ មានស្រីបម្រើការពី ៤ ទៅ ៧នាក់. ខ្លួនមិនអនុញ្ញាតឱ្យស្រីៗបម្រើការរួមភេទជាមួយភ្ញៀវនៅក្នុងហាងទេ។ ការធ្វើអាជីវកម្មនេះខ្លួនមានច្បាប់អនុញ្ញាតត្រឹមត្រូវពីខណ្ឌ។ ភ្ញៀវមកធ្វើម៉ាស្សា បើគេត្រូវការយកស្រីៗទៅក្រៅនៅក្នុងម៉ោងធ្វើការ គឺពីម៉ោង ៧ព្រឹក ដល់ម៉ោង ០១រំលងអាធ្រាត្រ ត្រូវបង់ប្រាក់ ៤ម៉ឺនរៀល ឬ ១០ដុល្លារ ជាមុនសិន បើក្រៅពីម៉ោងនេះខ្លួនមិនគិតលុយទេ. ឯស្រីៗចេញទៅក្រៅគេឱ្យខ្លួន ១០.០០០រៀល នៅពេលត្រឡប់ចូលកន្លែងវិញ។ ការចេញក្រៅរបស់ស្រីៗទាំងនោះ គឺជាសិទ្ធិរបស់ពួកគេ តែនៅក្នុងផ្ទះខ្លួនមិនអនុញ្ញាតឱ្យរួមភេទទេ។ ចំពោះប្រាក់បានមកពីការធ្វើម៉ាស្សា កោស ជប់ខ្យល់ ខ្លួនប្រមូលទុក លុះដល់ដាច់ខែ ទើបបើកឱ្យ. ឯការស្នាក់នៅស៊ីចុកបាយទឹក ខ្លួនជាអ្នកទទួលខុសត្រូវទាំងស្រុង។ ខ្លួនមិនដែលដឹងពីការរួមភេទនៅក្នុងហាងរបស់ស្រីៗម៉ាស្សាទេ ឯការដែលស្រីៗចេញក្រៅក៏មិនដែលប្រាប់ខ្លួនថា ទៅរួមភេទជាមួយភ្ញៀវដែរ។

៣- តាមចម្លើយសាក្សីជាស្ត្រីធ្វើម៉ាស្សាថា ខ្លួនធ្វើម៉ាស្សាមិនដែលរួមភេទនៅក្នុងហាងទេ បើភ្ញៀវត្រូវការគេនាំទៅខាងក្រៅ, ពេលត្រឡប់មកវិញឱ្យលុយម្ចាស់ហាង ១០.០០០រៀល។ ដោយឡែកសាក្សីឈ្មោ[redacted]ទាន់ធឿន ថា យូរៗមានភ្ញៀវរួមភេទនៅក្នុងបន្ទប់ម៉ាស្សាម្ដងៗដែរ, រួចខ្លួនឱ្យថៅកែ ១០.០០០រៀល។

៤- ការរួមភេទមានធ្វើជាញឹកញាប់រវាងស្ត្រីធ្វើម៉ាស្សា និងភ្ញៀវចូលម៉ាស្សា តែមិនប្រព្រឹត្តនៅក្នុងហាងជារហូតនោះទេ គឺច្រើនតែធ្វើនៅក្រៅហាង ឯនៅក្នុងហាង គឺយូរៗទើបមានម្ដងប៉ុណ្ណោះ ប៉ុន្តែទោះជាយ៉ាងណា រាល់ការប្រព្រឹត្តរួមភេទរបស់ស្រីម៉ាស្សា ជនជាប់ចោទតែងបានទទួលកម្រៃពីស្ត្រីម៉ាស្សាដែរ។

៥- មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ សញ្ចារកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅផ្ទះលេខ ១៩E₀ ផ្លូវស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១ តាមមាត្រា ២៨៤, ២៨៨ នៃក្រមព្រហ្មទណ្ឌ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ១៤០ កបព "ទ" ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែសេចក្ដីសម្រេចស្ដីពីការអនុវត្តទោស គួរកែប្រែ។

**<u>ហេតុដូច្នេះ</u>**

**<u>វិនិច្ឆ័យសេចក្ដី</u>**

១- ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៤០ ចុះថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ[redacted] ចន្ធូ ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៤០ កបព "ទ" ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែក្នុងចំណុចទី ១ ស្ដីពីការអនុវត្តទោស ត្រូវកែប្រែថា: ៦

"កែជនជាប់ចោទត្រូវអនុវត្តទោសក្នុងពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរធម្មតា"។

ក្រៅពីនេះទុកនៅដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ ប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 04 ខែ 06 ឆ្នាំ ២០១៤
ក្រឡាបញ្ជី